ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦០៦០ កសក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការដ្ឋាន និងកិច្ចការកសិកម្ម
លេខ 323
ថ្ងៃទី 12 07 2017
បញ្ជូន

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ: របាយការណ៍ស្តីពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករប្រចាំខែមិថុនាដើមឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នៅរយៈពេល៦ខែដើមឆ្នាំ២០១៧នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេស ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ (National Phytosanitary Database, NPD/GDA ពីម៉ោង ០៧:០០ ព្រឹក ថ្ងៃទី ០១.០១.២០១៧ រហូតដល់ម៉ោង ១៧:០០ ថ្ងៃទី ៣០.០៦.២០១៧) ដែលជាតួលេខនៃការនាំចេញ តាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញ មានដូចខាងក្រោម៖

១- ស្ថានភាពនៃការនាំចេញអង្ករ៖

- បរិមាណអង្ករនាំចេញក្នុងខែមិថុនាមានចំនួន ៣០ ៩២៥ តោន មានការថយចុះចំនួន ២ ៩៣៧ តោន (-៩,៥០%) តិចជាងបរិមាណនាំចេញក្នុងខែមិថុនាដើមឆ្នាំ២០១៦ (ដែលមាន ៣៣ ៨៦២ តោន)។ បរិមាណអង្ករដែលនាំចេញក្នុងរយៈពេល៦ខែដើមឆ្នាំនេះ មានចំនួន ២៨៨ ៥៦២ តោន ដែលមានកំណើន ២០ ៣៧២ តោន (+៧,៦០%) លើសបរិមាណនាំចេញ៦ខែដើមឆ្នាំមុន (សូមបង្ហាញជូនក្នុងតារាងទី១ នៃឧបសម្ព័ន្ធ១)

- អង្ករក្រអូបគ្រប់ប្រភេទនាំចេញក្នុងរយៈពេល៦ខែ មានបរិមាណ ១៥១ ០៨៨តោន ស្មើនឹង៥២,៣៦% អង្ករ ស គ្រប់ប្រភេទមានចំនួន ១០៣ ៧៨០ តោន ស្មើនឹង ៣៥,៩៦% និងអង្ករចំហុយមានចំនួន ៣៣ ៦៩៤តោន ស្មើនឹង១១,៦៨%។ ក្នុងចំណោមអង្ករក្រអូបនោះ អង្ករក្រអូបចម្រុះមានបរិមាណនាំចេញ ៦៩ ២៩៩ តោនស្មើនឹង ២៤,០២% អង្ករផ្កាវ៉ាដ្ជល/ផ្កាម្លិះមាន ៧៣ ០១១ តោន ស្មើនឹង២៥,៣០% (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

- ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៧ អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៥៦ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៩៤ ៧២០តោន) ប្រទេសបារ៉ាំងលំដាប់ទី២ (៣៧ ៣២១តោន) ប្រទេសប៉ូឡូញលំដាប់ទី៣ (២៥ ៦៣៩តោន) ប្រទេសអង់គ្លេសលំដាប់ទី៤ (២១ ២៦៩តោន) ប្រទេសណេដឺឡែនលំដាប់ទី៥ (១៤ ៨៩៤តោន) ប្រទេសប៊ែលហ្ស៊ីកលំដាប់ទី៦ (១១ ៤៣២តោន) ប្រទេសឆេកលំដាប់ទី៧ (៩ ៩០៧តោន) ប្រទេស កាបុងលំដាប់ទី៨ (៨ ៨៨២តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៩ (៨ ១៣០តោន) និងប្រទេសអ៊ីតាលី ឈរលំដាប់ទី១០ (៧ ០៩៩តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហភាពអឺរ៉ុប២៥ប្រទេស មានបរិមាណសរុប ១៥៤ ២១១ តោន (៥៣,៤៤%) ទិសដៅអាស៊ាន៤ប្រទេសមានបរិមាណសរុប ១៤ ៥៥៨តោន (៥,០៥%) និងទិសដៅដទៃទៀតចំនួន២៧ប្រទេសមានបរិមាណសរុប ១១៩ ៧៩៣ តោន (៤១,៥១%) (សូមបង្ហាញជូនក្នុងតារាងទី៣ នៃឧបសម្ព័ន្ធ)

- ការនាំចេញអង្ករមាន ៧២ ក្រុមហ៊ុន ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយ៖ (ទី១).ក្រុមហ៊ុន Cristal Rice មានចំនួន ៣០ ៩៦១ តោន (ទី២).ក្រុមហ៊ុន Baitang Kampuchea មានចំនួន ២៧ ៤១៥ តោន (ទី៣).ក្រុមហ៊ុន Apsara Rice មានចំនួន ២៣ ៧៣៤ តោន (ទី៤). Khmer Food Group មានចំនួន ២១ ៨៣១ តោន (ទី៥).ក្រុមហ៊ុន Amru Rice មានចំនួន ១៩ ៦៦៣ តោន (ទី៦). ក្រុមហ៊ុន Golden Rice មានចំនួន ១៦ ៧៧៤ តោន(ទី៧). ក្រុមហ៊ុន City Rice Import Export មានចំនួន ១៥ ០៤៦ តោន (ទី៨).ក្រុមហ៊ុន Nikoline Investment

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

មានចំនួន ១៨ ៣៧៥ តោន (ទី៩).ក្រុមហ៊ុន KOL VEASNA investment មានចំនួន ១១ ៦៧៥ តោន និង(ទី១០). ក្រុមហ៊ុន Signatures of Asia មានចំនួន ៩ ៩៥៧ តោន (សូមបង្ហាញជូនក្នុងតារាងទី៨ នៃឧបសម្ព័ន្ធ)។

២-**សន្និដ្ឋាន**ៈ

បរិមាណអង្ករនាំចេញសរុបក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៧ មានចំនួន ២៨៨ ៥៦២តោន ដែលបរិមាណនេះមានកំណើនប្រមាណ+៧,៦០% ធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៦។ កំណើនក្នុងខែមករាឆ្នាំនេះធៀបនឹងខែមករាឆ្នាំមុន មាន១០,៩% កំណើនក្នុងខែកុម្ភៈឆ្នាំនេះធៀបនឹងខែកុម្ភៈឆ្នាំមុន មាន ១៧% កំណើនក្នុងខែមេសាឆ្នាំនេះធៀបនឹងខែមេសាឆ្នាំមុន មាន១៥,៦% និងកំណើនក្នុងខែឧសភាឆ្នាំនេះធៀបនឹងខែឧសភាឆ្នាំមុនមាន ៨,៩០%។ ផ្ទុយទៅវិញ ការថយចុះក្នុងខែមីនាឆ្នាំនេះធៀបនឹងខែមីនាឆ្នាំមុនមានរហូតដល់ -១៦% និងខែមិថុនានេះធៀបខែមិថុនាឆ្នាំមុនមានដល់ទៅ -៩,៥០% ដែលធ្វើឱ្យមានការនាំចេញ៦ខែដើមឆ្នាំមានកំណើនតែ +៧,៦០% ធៀបនឹង៦ខែដើមឆ្នាំ២០១៦ហើយក៏ជាបរិការណ៍មួយក្នុងកាលៈទេសៈដែលយើងកំពុងប្រឈមទល់នឹងការចាប់ផ្តើមអនុវត្តច្បាប់ថ្មីរបស់សហភាពអឺរ៉ុប នៅដើមខែកក្កដា ឆ្នាំ២០១៧ ដែលកំណត់មិនឲ្យមានសំណល់ថ្នាំកសិកម្ម Tricyclazole លើសពី ០,០១ មីលីក្រាម ក្នុង១គីឡូក្រាមអង្ករ។

លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេនាធិការ របស់ក្រុមការងារទី៩ នឹងខិតខំបន្តពង្រីកវិសាលភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ (សមត្ថកិច្ចដែលពាក់ព័ន្ធនឹងបែបបទនាំចេញអង្ករ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនឡូហ្ស្ទីក ក្រុមហ៊ុនដឹកជញ្ជូន។ល។ ដែលកំពុងមានសកម្មភាពពាក់ព័ន្ធនឹងការនាំចេញអង្ករ) ក្នុងការរៀបចំថែទាំស្រូវអង្ករមុនការនាំចេញ និងបំពេញបែបបទដោយអនុលោមតាមលក្ខខ័ណ្ឌតម្រូវរបស់ប្រទេសនាំចូល និងរាល់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយប្រទេសនាំចូលឲ្យបានសមស្របតាមស្តង់ដារភ្ជាប់គាមអនាម័យទាំងបរិមាណ គុណភាព និងនីតិវិធីជាធរមាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ-កម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតពីខ្ញុំបាទ។

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ: របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែ មិថុនា ឆ្នាំ២០១៧

(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN JUNE , 2017)

(Base on NPD/GDA from 07:00/01.01.2017 to 17:00/30.06.2017 and all number are English punctuation)

តារាងទី១.បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១៣ - ២០១៧, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2013-2017, in tones)

	Month/ Year	2013	2014	2015	2016	2017	VARIATION
1	មករា (January)	25,726	21,536	35,921	44,033	48,820	+10.90%
2	កុម្ភៈ (February)	24,089	27,037	37,676	51,912	60,731	+17.00%
3	មីនា (March)	45,413	35,757	75,867	66,275	57,127	-16.00%
4	មេសា (April)	23,276	35,961	51,719	39,550	45,716	+15.60%
5	ឧសភា (May)	28,350	27,971	41,842	32,558	45,243	+38.90%
6	មិថុនា (June)	29,105	29,666	40,800	**33,862**	**30,925**	-9.50%
Sub-Total for 6 months		175,959	177,928	283,825	**268,190**	**288,562**	+7.60%
7	កក្កដា (July)	31,411	26,060	28,492	24,087		
8	សីហា (August)	29,358	29,871	29,819	27,799		
9	កញ្ញា (September)	29,395	35,511	26,969	41,429		
10	តុលា (October)	28,031	35,418	39,064	60,016		
11	វិច្ឆិកា (November)	37,855	31,137	48,748	58,168		
12	ធ្នូ (December)	46,847	51,136	81,479	62,455		
GRAND TOTAL		378,856	387,061	538,396	542,144		

តារាងទី២.ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង៦ខែដើមឆ្នាំ ២០១៧, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in June 2017, in tones)

	ប្រភេទអង្ករ TYPE OF RICE	មករា JAN	កុម្ភៈ FEB	មីនា MAR	មេសា APR	ឧសភា MAY	មិថុនា JUN	សរុប (TOTAL) MT	%
I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:									
1	ចម្រុះ (F.SENKRAOB, NEANG SAUY....)	13,907	21,767	12,573	9,532	6,102	5,418	69,299	24.02
2	នាងម្ជិស (F. NEANG MALIS)	117	166	167	267	145	146	1,008	0.35
3	សូមាលី .(F. SOMALY)	96	167	168	118	234	24	807	0.28
4	ផ្កាំដូល /ផ្កាម្ជិស/ (J.PHKA RUMDUOL/ MALIS)	13,242	11,085	14,258	11,876	13,759	8,791	73,011	25.30
5	សរីរាង្គ (J.ORGANIC)	1,019	1,174	1,691	696	1,219	1,116	6,915	2.40
6	ភ្ជ . (F. PEARL)	24	-	24		-	-	48	0.02
	SUB-TOTAL	**28,405**	**34,359**	**28,881**	**22,489**	**21,459**	**15,495**	151,088	52.36
II.អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:									
1	ចម្រុះគ្រាប់វែង (LONG GRAIN)	16,823	19,017	19,801	17,914	15,988	9,447	98,990	34.30
2	ប្រណីតគ្រាប់វែង (PREMIUM LONG GRAIN)	935	1,092	553	237	858	1,115	4,790	1.66
	SUB-TOTAL	**17,758**	**20,109**	**20,354**	**18,151**	**16,846**	**10,562**	103,780	35.96
III.អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:									
1	ចំហុយគ្រាប់វែង (LONG GRAIN PABOILLED)	2,657	6,263	7,892	5,076	6,938	4,868	33,694	11.68
	SUB-TOTAL	**2,657**	**6,263**	**7,892**	**5,076**	**6,938**	**4,868**	33,694	11.68
GRAND TOTAL		48,820	60,731	57,127	45,716	45,243	30,925	288,562	100.00

តារាងទី៣.ទិសដៅនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល៦ខែដើមឆ្នាំ ២០១៧, គិតជាតោន

(Table 3. Export Destination of Cambodian Rice in 6 Month of 2017, in tones)

	ប្រទេសគិសដៅ COUNTRY DESTINATION	មករា JAN	កុម្ភៈ FEB	មីនា MAR	មេសា APR	ឧសភា MAY	មិថុនា JUN	សរុប (TOTAL) MT
	I.សមាជិកសហគមន៍អ៊ីរ៉ុប /EUROPEAN UNION							
1	FRANCE	8,230	7,088	5,688	6,842	5,611	3,862	37,321
2	POLAND	4,760	4,376	3,778	3789	6,333	2,603	25,639
3	UNITED KINGDOM	2,432	3,954	4,285	4588	5,363	647	21,269
4	NETHERLAND	2,219	2,960	2,471	2056	3,217	1,971	14,894
5	BELGIUM	1,277	1,829	2,692	1642	1,983	2,009	11,432
6	CZECH REPUBLIC	1,034	2,023	2,948	1356	1,485	1,061	9,907
7	ITALY	2,001	843	1,607	427	1,305	916	7,099
8	GERMANY	1,332	944	1,222	1093	961	357	5,909
9	SPAIN	749	815	707	279	1,014	546	4,110
10	SWEEDEN	613	337	376	369	926	310	2,931
11	PORTUGAL	749	336	917	23	446	366	2,837
12	LATIVIA	1,000	525	-	-	125	625	2,275
13	DENMARK	273	335	240	195	450	399	1,892
14	GREECE	358	340	74	225	346	73	1,416
15	CROATIA	-	400	350	250	25	-	1,025
16	LITHUANIA	-	546	275	120	-	-	941
17	AUSTRIA	147	115	120	72	91	122	667
18	HUNGARY	89	125	66	123	125	138	666
19	SLOVENIA	-	150	150	125	-	96	480
20	ROMANIA	72	72	48	144	48	-	425
21	CYPRUS	24	24	124	74	100	50	396
22	ESTONIA	25	100	75	-	-	75	275
23	FINLAND	63	-	72	-	65	50	250
24	IRELAND	24	18	24	-	-	17	83
25	MALTA	-	-	24	-	24	24	72
	SUB-TOTAL	**27,471**	**28,255**	**28,333**	**23,792**	**30,043**	**16,317**	**154,211=53.44%**
	II. សមាជិកអាស៊ាន/ASEAN MEMBER STATE							
1	MALAYSIA	529	529	2,162	2092	1,553	1,265	8,130
2	BRUNEI	-	924	924	924	924	882	4,578
3	VIETNAM	-	-	220	2,000	-	-	2,220
4	SINGAPORE	138	162	334	456	268	492	1,850
	SUB-TOTAL	**667**	**1,615**	**3,420**	**3472**	**2,745**	**2,639**	**14,558=5.05%**
	III.ទិសដៅផ្សេងទៀត /OTHERS DESTINATION							
1	CHINA	18,383	28,004	21,095	13,950	7,337	5,951	94,720
2	GABON	-	1,292	2530	1,277	2,524	1,259	8,882
3	SOUTH AFRICA	-	-	25	-	-	3,000	3,025
4	TURKEY	500	506	-	-	1,496	-	2,502
5	HONG KONG	1,006	88	105	136	102	242	1,679
6	RUSSIAN FED	245	-	297	172	75	500	1,289
7	BULGARIA	-	-	250	125	375	400	1,150
8	SENEGAL	-	250	250	200		-	700
9	USA	58	80	40	229	100	95	602
10	IRAQ	-	230	-	100		207	537
11	MAYOTTE	96	148	-	74	175	24	517
12	NEWZEALAND	23	47	114	70	117	77	448
13	AUSTRALIA	142	38	-	69	25	-	274
14	SAUDI ARABIA	-	50	96	-	-	122	268
15	CONGO	120	-	120	-	-	-	240
16	CANADA	85	-	62	-	-	42	189
17	TAIWAN	-	-	120	-	-	-	120
18	MACAU					105	-	105
19	KENYA	-	50	-	-	-	50	100
20	UKRAINE	-	-		25	24	-	49
21	CAMAROON	-	48	-	-	-	-	48
22	MADACASCAR	-	-	25	-	-	-	25
23	NAMIBIA	-	-	25	-	-	-	25
24	GHANA	-	-		25	-	-	25
25	REUNION	24	-	-	-	-	-	24
26	MOLDOVA	-	24	-	-	-	-	24
27	KOREA	-	6	-	-	-	-	6
	SUB-TOTAL	**20,682**	**30,861**	**25,374**	**18,452**	**12,455**	**11,969**	119,793=41.51%
	GRAND TOTAL	48,820	60,731	57,127	45,716	45,243	30,925	288,562=100%

តារាងទី៤.ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជា៦ខែដើមឆ្នាំ ២០១៧,គិតជាតោន

(Table 4.Cambodian Rice Exporters and export quantity 6 Months of 2017, in tones)

	ក្រុមហ៊ុននាំចេញអង្គរ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	សរុប (TOTAL)	
	RICE EXPORTERS	JAN	FRA	MAR	APR	MAY	JUN	MT	%
1	CRISTAL RICE (Kampuchea) co., ltd.	5,948	6,553	3,961	5,659	5,165	3,675	30,961	10.73
2	BAITANG (KAMPUCHEA) PLC.	9,270	4,516	4,903	993	4,487	3,246	27,415	9.50
3	APSARA RICE (CAMBODIA) CO., LTD	5,347	6,774	2,110	3,460	3,700	2,343	23,734	8.22
4	KHMER FOODS GROUP CO.,LTD.	5,849	3,866	3,573	3,570	2,898	2,075	21,831	7.57
5	AMRU RICE (CAMBODIA) CO.,LTD	3,509	2,928	3,153	3,546	3,152	3,375	19,663	6.81
6	GOLDEN RICE (CAMBODIA) CO.,LTD.	3,480	2,484	3,167	3,637	2,227	1,779	16,774	5.81
7	CITY RICE IMPORT EXPORT CO., LTD.	3,035	2,519	3,961	1,839	2,387	1,305	15,046	5.21
8	NIKOLINE INVESTMENT CO., LTD.	1,515	1,774	3,919	3,282	3,245	640	14,375	4.98
9	KOL VEASNA investment co., ltd.	2,250	3,650	2,875	1,975	-	925	11,675	4.05
10	SIGNATURES OF ASIA CO.,LTD	1,915	1,638	1,965	2,181	1,459	799	9,957	3.45
11	PRIMALIS CORPORATION LTD.	1,293	2,530	-	2,525	1,277	1,259	8,884	3.08
12	GREEN TRADE COMPANY	3,000	2,250	2,700	-	250	-	8,200	2.84
13	INTERNATIONAL RICE TRADING (CAMBODIA) CO.,LTD.	1,874	1,243	2,200	549	1,077	1,049	7,992	2.77
14	GOLDEN DAUN KEO RICE MILL CO., LTD	2,084	1,262	546	988	976	682	6,538	2.27
15	W.K.R TRADING CO.,LTD	1,325	936	1,616	1,494	718	440	6,529	2.26
16	T.O.T (TRUST OUR TRADE) CO., LTD.	368	1,231	942	1,567	1,856	543	6,507	2.25
17	INDOCHINA RICE MILL LIMITED	2,164	1,068	1,101	428	484	448	5,693	1.97
18	SSCORP(CAMBODIA) CO.,LTD	808	1,398	772	512	646	375	4,511	1.56
19	LOR EAK HENG SEK MEAS RICE CO., LTD	613	1,525	799	157	931	194	4,219	1.46
20	SOMA TRADING COMPANY LIMITED	625	625	-	1,050	500	1,224	4,024	1.39
21	HERBA (Cambodia) Co.,ltd	300	899	295	680	545	990	3,709	1.29
22	BATTAMBANG RICE INVESTMENT CO., LTD	685	331	452	546	162	546	2,722	0.94
23	THMOR KORL RICE IMPORT EXPORT CO., LTD	-	276	-	475	1,151	667	2,569	0.89
24	WHITE GOLD IMPORT EXPORT CO,. LTD.	302	809	46	269	299	319	2,044	0.71
25	PHENG LEANG SENG IMPORT EXPORT	-	-	-	-	2,023	-	2,023	0.70
26	HUNG HIEP (CAMBODIA) CO., LTD	-	1,300	170	178		207	1,855	0.64
27	CK RICE TRADING CO., LTD.	260	308	549	189	308	188	1,802	0.62
28	Golden Star Rice Mill and Import Export Co., Ltd	-	448	315	374	498	-	1,635	0.57
29	SARY KUNTHEA	-	250	-	-	1,250	-	1,500	0.52
30	Mekong Oryza trading co., ltd.	1,094	75	75	8	50	-	1,302	0.45
31	AMRU and Hanwha international co., ltd	479	112	92	83	168	297	1,231	0.43
32	COMMODITY IN FOCUS CO., LTD.	150	-	350	150	200	275	1,125	0.39
33	BOOST RICHE (CAMBODIA) CO., LTD.	-	240	-	792	72	19	1,123	0.39
34	FED RICE BATTAMBANG LTD	350	200	159	248	-	-	957	0.33
35	LIM KHEANG HOUT IMPORT EXPORT CO., LTD.	167	-	311	249	100	-	827	0.29
36	OVERSEAS FOODS IMPORT EXPORT CO.,LTD	122	148	100	298	-	75	743	0.26
37	GLOBAL ECOLOGICAL RICE (CAMBODIA) CO., LTD	-	40	490	50	-	-	580	0.20
38	CAPITAL FOOD IVVESMENT IMPORT EXPORT CO.,LTD	-	-	-	275	250	23	548	0.19
39	OU TONG DEVELOPMENT (CAMBODIA) CO., LTD	109	60	79	60	37	130	475	0.16
40	PHOU POY DEVELOPMENT IMPORT EXPORT CO., LTD	68	115	98	22	46	120	469	0.16
41	CAM-GRAIN DEVELOPMENT CO., LTD.	-	-	165	-	-	300	465	0.16
42	Cambodia diamond seafood and agriculture Co.,ltd	-	-	140	145	163	-	448	0.16
43	CAMBODIAN li shine international trade co.,ltd	-	16	100	239	-	-	355	0.12
44	ANGKOR KASEKAM ROONGROEUNG CO.,LTD.	53	70	24	-	119	69	335	0.12
45	DOMNAK TEUK GROUP CO.,LTD	-	48	73	49	49	96	315	0.11
46	KAMPONG THOM RICE MILL LIMITED.	25	-	100	50	76	50	301	0.10
47	PALM RICE CO.,LTD	-	-	-	-	284	-	284	0.10
48	CHHUN THOM RICE MILL	-	-	-	-	250	-	250	0.09
49	Cambodian organic farm enterprise (c.o.f.e) co., ltd	60	17	24	64	40	39	244	0.08
50	AVIC ENERGY (CAMBODIA) CO.,LTD	-	220	-	-	-	-	220	0.08
51	Jasmine Rice Mill Factory Co., Ltd.	-	44	66	44	-	44	198	0.07
52	AROMARICE IMPORT EXPORT CO., LTD	25	46	-	69	-	-	140	0.05
53	T.M.K investment co., ltd	-	121	-	-	-	-	121	0.04
54	VONG BUNHENG IMPORT EXPORT CO., LTD	-	-	96	18	-	-	114	0.04
55	MUFAVOR INTERNATIONAL (CAMBODIA) INC.	43	25	-	43	-	-	111	0.04
56	V-LOTTE trading co., ltd	50	-	-	-	-	50	100	0.03
57	UNI-NATRAL CO.,LTD	-	-	-	66	22	-	88	0.03
58	BAYON JASMINE RICE CO.,LTD	-	-	72	-	-	-	72	0.02
59	EANG heang import export co., ltd	-	24	-	48	-	-	72	0.02
60	TECH SOON AGRO INDUSTRY CO.,LTD	-	72	-	-	-	-	72	0.02
61	LK INTERNATIONAL GROUP PLC.	67	-	-	-	-	-	67	0.02
62	xiangshan rice (cambodia) co.,ltd.	-	-	25	32	-	-	57	0.02
63	HUA FENG YUAN RICE VERMICELLI (Cambodia)	-	-	36	18	-	-	54	0.02
64	LBN ANGKAR (KAMPUCHEA) CO., LTD	-	-	25	-	-	25	50	0.02
65	NGY HENG DROUP CO.,LTD	-	-	-	-	48	-	48	0.02
66	GREAT GREEN& GRE MENT ASIA PACIFIC (CAM) CO.,LTD	-	-	-	-	46	-	46	0.02
67	KHUN nguon rice export co., ltd.	-	20	-	-	-	20	40	0.01

68	MILIN RICE (CAMBODIA) IMPORT EXPORT CO.,LTD	-	-	30	-	-	-	30	0.01
69	BAYON CEREAL CO., LTD	25	-	-	-	-	-	25	0.01
70	CEREBRUM TRADING CO.,LTD	-	-	-	-	25	-	25	0.01
71	RICEPADDY FIELDS (CAMBODIA) CO., LTD.	25	-	-	-	-	-	25	0.01
72	M.S.C.K. TRADING LIMITED	-	23	-	-	-	-	23	0.01
GRAND TOTAL		60,731	57,127	48,820	45,716	45,243	30,925	288,562	100

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៧

អ្នករៀបចំសរុបទិន្នន័យ

ជិន ឌារ៉ូ

ឃ្លានឃើញ និង ឯកភាព

ប្រធានលេខាធិការដ្ឋាន

ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ

ឯកឧត្តមបណ្ឌិត ហ៊ាន ឋណ្ឌហាន